ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០៣០ សសរ.ធទឧ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ច
## ក្រសួងធនធានទឹក និងឧតុនិយម

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធានអាជ្ញាធរទន្លេសាប
## និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ស្ដីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា



# អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៦ ៦៧០
#364, Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670

- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ថោ ជេដ្ឋា** | រដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម | **ឈា ម៉ុនរិទ្ធ** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-ឯកឧត្តម | **ចាន់ យុត្ថា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **ម៉ុន ហ៊ាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥-ឯកឧត្តម | **ជីវ ស៊ុនហេង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦-ឯកឧត្តម | **អាន ពេជ្រ ហត្ថដា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧-ឯកឧត្តម | **តែ ណាវុធ** | អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៨-ឯកឧត្តម | **ហៃល តូនី** | អនុប្រធានអាជ្ញាធរទន្លេសាប | សមាជិក |
| ៩-ឯកឧត្តម | **ឃិន ខួនភូលេនីន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០-ឯកឧត្តម | **នាក់ ដាង** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១-ឯកឧត្តម | **អឿង ចន្ថា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២-លោកជំទាវ | **វ៉ាន់ ចាន់ថូ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣-ឯកឧត្តម | **អ៊ុក វុទ្ធី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៤-ឯកឧត្តម | **ឝួន ចន្ថា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៥-ឯកឧត្តម | **ឈុន ពុទ្ធារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស | សមាជិក |
| ១៦-ឯកឧត្តម | **ហ៊្វង ស៊ុនថាន** | អគ្គាធិការ | សមាជិក |
| ១៧-ឯកឧត្តម | **ស្វ សុភ័ន្ទ** | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ១៨-ឯកឧត្តម | **សរ គឹមសាន្ត** | អគ្គលេខាធិការនៃអាជ្ញាធរទន្លេសាប | សមាជិក |
| ១៩-លោក | **នូ សុបិន** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២០-ឯកឧត្តម | **ម៉េង ប៉ូគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល | លេខាធិការ។ |

**ប្រការ២ .-**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចដូចខាងក្រោម៖

១-ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលប្រកបដោយសង្គតិភាព និងសុខដុមនីយកម្មក្នុងក្រសួង និងស្ថាប័ន។

២-សិក្សាស្រាវជ្រាវ វិភាគ និងដាក់ចេញនូវយុទ្ធសាស្ត្រដើម្បីលើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន។

៣-ពិនិត្យនិងធានាការផ្សារភ្ជាប់រវាងគោលបំណងនិងផែនការសកម្មភាពនៃការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល ជាមួយនឹងគោលនយោបាយនិងយុទ្ធសាស្ត្រនៅក្នុងវិស័យរបស់ក្រសួង និងស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រ។

៤-សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ ពាក់ព័ន្ធនឹងការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចនិងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួង និងស្ថាប័ន។

៥-ធានានូវការផ្សារភ្ជាប់គ្នារវាងការអភិវឌ្ឍសមត្ថភាពមន្ត្រី ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការលើកកម្ពស់គុណភាពការងារឆ្លើយតបនឹងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។

៦-ជំរុញការកែទម្រង់និងបរិវត្តកម្មឌីជីថល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការងារក្នុងក្រសួង និងស្ថាប័ន។

៧-ផ្តល់នូវធាតុចូលឬអនុសាសន៍ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនិងគំនិតផ្តួចផ្តើមថ្មីៗដល់ការដ្ឋានកែទម្រង់នានារបស់រាជរដ្ឋាភិបាល ដើម្បីមានវិធានការគាំទ្រដល់ការលើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន។

៨-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន និងផ្តល់របាយការណ៍ទៀងទាត់តាមការកំណត់ ជូនគណៈកម្មាធិការកែទម្រង់ដែលមានការពាក់ព័ន្ធ។

**ប្រការ៣ .-**

ប្រធានគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម អាចប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានណាម្នាក់ ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសបាន។

**ប្រការ៤ .-**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម ត្រូវប្រជុំយ៉ាងតិចរៀងរាល់ ៣(បី)ខែម្តង ឬតាមការចាំបាច់ តាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការ អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥ .-**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរ ដៃគូអភិវឌ្ឍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សាឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៦ .-**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម មានសិទ្ធិប្រើត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម សម្រាប់កិច្ចដំណើរការរបស់ខ្លួន។

**ប្រការ៧ .-**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម មានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ជាលេខាធិការដ្ឋាន។

របៀបសម្ព័ន្ធចំណុះអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលដែលមានស្រាប់ ត្រូវផ្តល់ការគាំទ្រក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការ ដូចមានកំណត់ក្នុងប្រការ២នៃសេចក្តីសម្រេចនេះ។

**ប្រការ៨ ._**

ក្នុងក្របខ័ណ្ឌជាលេខាធិការដ្ឋាន អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលត្រូវបំពេញភារកិច្ចដូចតទៅៈ

១-គាំទ្រនិងសម្របសម្រួលការងារ ដើម្បីធានាដំណើរការ ការបំពេញតួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការ។

២-គាំទ្រការសិក្សាស្រាវជ្រាវ វិភាគ និងស្នើនូវយុទ្ធសាស្ត្រលើការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន។

៣-សហការនិងសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួង ក្រសួង ស្ថាប័ននានា អង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រនិងជំរុញការអនុវត្តការងារកែទម្រង់តាមការតម្រង់ទិសរបស់គណៈកម្មាធិការ។

៤-សម្របសម្រួលរៀបចំផែនការសកម្មភាពនិងថវិកា ព្រមទាំងការកំណត់សូចនាករសមិទ្ធកម្មជាក់លាក់ដើម្បីធានាការអនុវត្តការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន។

៥-សម្របសម្រួលការរៀបចំ និងជំរុញការអនុវត្តផែនការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នរបស់ក្រសួងនិងស្ថាប័ន ឆ្លើយតបនឹងគោលបំណងនិងយុទ្ធសាស្ត្រនៃការកែទម្រង់របស់រាជរដ្ឋាភិបាល រួមទាំងគម្រោងនិងកម្មវិធី ដើម្បីអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីជំនាញដែលដឹកនាំ គាំទ្រ និងចូលរួមអនុវត្តការងារកែទម្រង់ក្នុងក្រសួង។

៦-ផ្តល់យោបល់និងលើកសំណើដោះស្រាយជូនគណៈកម្មាធិការ លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលក្នុងក្រសួង និងស្ថាប័ន។

៧-សម្របសម្រួលការងារប្រចាំថ្ងៃនិងបំពេញការងាររដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអនុវត្តតួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការ។

៨-រៀបចំឯកសារ របាយការណ៍កិច្ចប្រជុំនិងសិក្ខាសាលានានាសម្រាប់គណៈកម្មាធិការ ព្រមទាំងរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំនៃការអនុវត្តការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន ជូនប្រធានគណៈកម្មាធិការ។

៩-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលក្នុងក្រសួង និងស្ថាប័ន។

១០-រៀបចំចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសមិទ្ធផលនានានៃការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង និងស្ថាប័ន។

១១-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធានគណៈកម្មាធិការ។

**ប្រការ៩ ._**

គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងធនធានទឹក និងឧតុនិយម មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងធនធានទឹក និងឧតុនិយម និងប្រភពធនធានស្របច្បាប់ផ្សេងទៀត។

**ប្រការ១០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស អគ្គាធិការ អាជ្ញាធរទន្លេសាប គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា គ្រប់អង្គភាពចំណុះក្រសួង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥ រោច ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ថោ ជេដ្ឋា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ដូចប្រការ១១
- ឯកសារ កាលប្បវត្តិ